**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**លេខ** ៦០៥/០៧ **គ.ជ.ប**

**ជម្រាបជូន**

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស**

**និងសហប្រតិបត្តិការអន្តរជាតិ**

**កម្មវត្ថុ** : សំណើសុំអញ្ជើញតំណាងអង្គការក្រៅរដ្ឋាភិបាលបរទេស តំណាងប្រទេសនានា និង តំណាងអង្គការអន្តរជាតិ ដើម្បីចូលរួមសង្កេតការណ៍ដំណើរការរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី ៤ ឆ្នាំ ២០០៨ ។

**យោង** : -ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ

-ប្រតិទិននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី ៤ ឆ្នាំ ២០០៨ ។

តាមកម្មវត្ថុ និង យោងខាងលើ ខ្ញុំសូមជម្រាបឯកឧត្តមឧបនាយករដ្ឋមន្ត្រីជ្រាបថា ដំណើរការរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី ៤ ឆ្នាំ ២០០៨ ប្រព្រឹត្តទៅចាប់ពីថ្ងៃទី ៥ ខែ កញ្ញា ឆ្នាំ ២០០៧ រហូតដល់ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៨ ។

ដើម្បីឱ្យដំណើរការរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ ២០០៨ ប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និង យុត្តិធម៌ ខ្ញុំសូមឯកឧត្តមឧបនាយករដ្ឋមន្ត្រីអញ្ជើញតំណាងអង្គការក្រៅរដ្ឋាភិបាលបរទេស តំណាងប្រទេសនានា និង តំណាងអង្គការអន្តរជាតិ ដើម្បីចូលរួមសង្កេតការណ៍ដំណើរការរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ ២០០៨ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចាប់ទទួលពាក្យអ្នកសង្កេតការណ៍អន្តរជាតិពីថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៧ រហូតដល់ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០៨ នៅទីស្តីការគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

សូមឯកឧត្តមឧបនាយករដ្ឋមន្ត្រី ទទួលនូវការគោរពរាប់អានដ៏ស្មោះអំពីខ្ញុំ ។

ភ្នំពេញ ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៧

**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

អ៊ឹម សួស្តី

សូមជូនភ្ជាប់មកជាមួយ :

-ប្រតិទិននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ឆ្នាំ២០០៨